# ការបោះឆ្នោតដោយមានកំណត់ត្រាព្រហ្មទណ្ឌ

*កំណត់ត្រាព្រហ្មទណ្ឌរបស់អ្នកមិនប៉ះពាល់ដល់សិទ្ធិបោះឆ្នោតរបស់អ្នកនៅរដ្ឋ Minnesota ទេ លុះត្រាតែបច្ចុប្បន្ននេះអ្នកកំពុងជាប់ពន្ធនាគារទទួលទោសពីបទឧក្រិដ្ឋ។*

## *ការបោះឆ្នោតបន្ទាប់ពីការកាត់ទោសពីបទឧក្រិដ្ឋ*

គិតចាប់ពីថ្ងៃទី 1 ខែមិថុនា ឆ្នាំ 2023 អ្នកអាចបោះឆ្នោតបានដរាបណាអ្នកមិនទាន់ជាប់ពន្ធនាគារពីទោសបទឧក្រិដ្ឋ ជាពលរដ្ឋអាមេរិក មានអាយុយ៉ាងតិច 18 ឆ្នាំនៅថ្ងៃបោះឆ្នោត និងជាពលរដ្ឋរស់នៅក្នុងរដ្ឋ Minnesota យ៉ាងហោចណាស់ 20 ថ្ងៃ។

## *ការបោះឆ្នោតបន្ទាប់ពីសិទ្ធិរបស់អ្នកត្រូវបានស្តារឡើងវិញ*

ប្រសិនបើអ្នកបានជាប់ពន្ធនាគារទទួលទោសពីបទឧក្រិដ្ឋ អ្នកអាចបោះឆ្នោតបាននៅពេលដែលការជាប់ពន្ធនាគារបានបញ្ចប់។ នៅពេលដែលសិទ្ធិបោះឆ្នោតរបស់អ្នកត្រូវបានស្តារឡើងវិញ អ្នកត្រូវតែចុះឈ្មោះបោះឆ្នោត។ អ្នកអាចចុះឈ្មោះ៖

### *កាលបរិច្ឆេទឆ្នាំ 2026*

***បោះឆ្នោតមុនកាលកំណត់***
*ថ្ងៃទី 26 ខែមិថុនា - ថ្ងៃទី 10 ខែសីហា*

***ចុះឈ្មោះជាមុន***
*ត្រឹមថ្ងៃទី 21 ខែកក្កដា*

***ការបោះឆ្នោតបឋម***
*ថ្ងៃអង្គារ ទី 11 ខែសីហា*

***បោះឆ្នោតមុនកាលកំណត់***
*ថ្ងៃទី 18 ខែកញ្ញា - ថ្ងៃទី 2 ខែវិច្ឆិកា*

***ចុះឈ្មោះជាមុន***
*ត្រឹមថ្ងៃទី 13 ខែតុលា*

***ថ្ងៃបោះឆ្នោត***
*ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា*

- តាមអនឡាញនៅ ***mnvotes.gov/register***
- ជាមួយនឹងទម្រង់ក្រដាស សូមផ្ញើមកវិញតាមប្រៃសណីយ៍ទៅកាន់ការិយាល័យរដ្ឋលេខាធិការនៃរដ្ឋ Minnesota ឬការិយាល័យរៀបចំការបោះឆ្នោតប្រចាំខោនធីរបស់អ្នក
- អញ្ជើញមកដោយផ្ទាល់នៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក

*បន្តនៅទំព័រក្រោយ...*

**ការិយាល័យរដ្ឋលេខាធិការនៃរដ្ឋ Minnesota**
*mnvotes.gov • ទូរសព្ទ៖ 1-877-600-VOTE • ផ្ញើសារ៖ 651-217-3862*

# ការបោះឆ្នោតដោយមានកំណត់ត្រាព្រហ្មទណ្ឌ

## *តើខ្ញុំអាចបោះឆ្នោតបានទេ ប្រសិនបើ...*

| | |
|---|---|
| ខ្ញុំត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសពីបទមជ្ឈិម ឬបទមជ្ឈិមធ្ងន់ធ្ងរ? | **បាទ/ចាស់** |
| ខ្ញុំកំពុងជាប់ពន្ធនាគារ ប៉ុន្តែបច្ចុប្បន្នមិនទាន់ត្រូវបានកាត់ទោសពីបទឧក្រិដ្ឋទេ? | **បាទ/ចាស់** |
| ខ្ញុំត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ប៉ុន្តែខ្ញុំមិនទាន់ត្រូវបានផ្តន្ទាទោសទេ? | **បាទ/ចាស់** |
| ខ្ញុំទទួលបានការផ្អាកការជំនុំជម្រះ? | **បាទ/ចាស់** |
| ខ្ញុំត្រូវបានកាត់ទោសពីបទឧក្រិដ្ឋនៅរដ្ឋមួយផ្សេងទៀត ប៉ុន្តែបច្ចុប្បន្នខ្ញុំមិនទាន់ជាប់ពន្ធនាគារទេ? | **បាទ/ចាស់** |
| ខ្ញុំកំពុងស្ថិតក្រោមការព្យួរទោសមានលក្ខខណ្ឌ ឬដោះលែងមានលក្ខខណ្ឌបន្ទាប់ពីការកាត់ទោសពីបទឧក្រិដ្ឋ? | **បាទ/ចាស់** |
| ខ្ញុំត្រូវបានកាត់ទោសពីបទឧក្រិដ្ឋ ហើយបច្ចុប្បន្នកំពុងស្ថិតក្នុងការដោះលែងពីពន្ធនាគារដើម្បីធ្វើការ? | **បាទ/ចាស់** |
| ខ្ញុំកំពុងរស់នៅក្នុងមណ្ឌលអប់រំកែប្រែជាជម្រើសសហព័ន្ធជំនួសឱ្យការឃុំខ្លួនមុនការកាត់ក្តី ការដោះលែងក្រោមការត្រួតពិនិត្យរបស់រដ្ឋ ឬគោលបំណងមិនមែនជាប់ពន្ធនាគារផ្សេងទៀត? **អ្នកគួរតែពិគ្រោះជាមួយមន្ត្រីព្យួរទោសរបស់អ្នក ប្រសិនបើអ្នកមានសំណួរអំពីថាតើអ្នកត្រូវបានចាត់ទុកថា "ជាប់ពន្ធនាគារ" ខណៈពេលដែលកំពុងរស់នៅក្នុងមណ្ឌលអប់រំកែប្រែ។** | **បាទ/ចាស់** |
| បច្ចុប្បន្នខ្ញុំកំពុងជាប់ពន្ធនាគារពីទោសបទឧក្រិដ្ឋនៅក្នុងពន្ធនាគារ គុក ឬ (សម្រាប់ការកាត់ទោសពីបទឧក្រិដ្ឋសហព័ន្ធ) មណ្ឌលអប់រំកែប្រែ? | **ទេ** |